ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# បទបញ្ជាផ្ទៃក្នុង
# សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត
# នៃព្រះរាជាណាចក្រកម្ពុជា (ស.ជ.ក.រ.ខ)

## *INTERNAL RULE*
## *National Association of Capital and Provincial Councils*
## *of the Kingdom of Cambodia (NACPC)*

# បទបញ្ជាផ្ទៃក្នុង

យោងលក្ខន្តិកៈសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត ដែលត្រូវបានមហាសន្និបាតលើកទី១ របស់សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត អនុម័តនាថ្ងៃទី...... ខែ........ ឆ្នាំ......... សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត កំណត់បទបញ្ជាផ្ទៃក្នុងសម្រាប់អនុវត្ត ដូចខាងក្រោម៖

## ១-អំពីអគ្គលេខាធិការ អគ្គលេខាធិការរង និងបុគ្គលិក បម្រើការងារក្នុងអគ្គលេខាធិការដ្ឋាន

ប្រការ ១.-

សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវជ្រើសរើស អគ្គលេខាធិការ ១រូប និងអគ្គលេខាធិការរង មួយចំនួន ដែលមានលក្ខណៈសម្បត្តិ៖

- មានអាយុយ៉ាងតិច ២៥ ឆ្នាំ
- មានអាកប្បកិរិយា និងសីលធម៌ល្អ
- មានសមត្ថភាព ជំនាញវិជ្ជាជីវៈ និងបទពិសោធន៍
- មានឆន្ទៈក្នុងការបំពេញការងារ

សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត អាចជ្រើសរើស បុគ្គលិកបម្រើការងារក្នុងអគ្គលេខាធិការដ្ឋានមួយចំនួនថែមទៀតក្នុងករណីចាំបាច់ តាមលទ្ធភាព និងទំហំការងាររបស់សមាគម។

ប្រការ ២.-

ការជ្រើសរើសអគ្គលេខាធិការ អគ្គលេខាធិការរង និងបុគ្គលិកបម្រើការងារនៅក្នុងអគ្គលេខាធិការដ្ឋាន ត្រូវធ្វើជាចំហ ផ្សព្វផ្សាយជាសាធារណៈ និងត្រូវបង្កើតគណៈកម្មការដើម្បីជ្រើសរើស។

ប្រការ ៣.-

អគ្គលេខាធិការ អគ្គលេខាធិការរង និងបុគ្គលិក ដែលត្រូវបានជ្រើសរើសឲ្យចូលបម្រើការងារក្នុងអគ្គលេខាធិការដ្ឋាន ត្រូវឆ្លងកាត់ការសាកល្បងរយៈពេល ៣ខែ។

ប្រការ ៤.-

ថ្នាក់ដឹកនាំសមាគម ត្រូវធ្វើការប្រជុំវាយតម្លៃលើលទ្ធផលការងារក្នុងរយៈពេលសាកល្បងរបស់អគ្គលេខាធិការ អគ្គលេខាធិការរង និងបុគ្គលិក មុននឹងសម្រេចតែងតាំងជាអគ្គលេខាធិការ អគ្គលេខាធិការរង និងបុគ្គលិកពេញសិទ្ធិ។

ប្រការ ៥.-

ថ្នាក់ដឹកនាំសមាគមមានសិទ្ធិបញ្ឈប់អគ្គលេខាធិការ និងអគ្គលេខាធិការរងក្នុងករណី ដូចខាងក្រោមៈ

-មានការស្នើសុំបញ្ឈប់ពីសមាជិកក្រុមប្រឹក្សាជាតិ យ៉ាងតិចមួយភាគបី ឬ

-មានការស្នើសុំបញ្ឈប់ពីសមាជិកគណៈកម្មាធិការប្រតិបត្តិជាតិ យ៉ាងតិចពីរភាគបី ឬ

-មានការសម្រេចពីថ្នាក់ដឹកនាំសមាគម យ៉ាងតិចពីរភាគបី។

ថ្នាក់ដឹកនាំសមាគមយ៉ាងតិចពីរភាគបីមានសិទ្ធិបញ្ឈប់បុគ្គលិកក្នុងអគ្គលេខាធិការដ្ឋាន តាមការស្នើសុំរបស់អគ្គលេខាធិការ។

ប្រការ ៦.-

អគ្គលេខាធិការ អគ្គលេខាធិការរង និងបុគ្គលិកត្រូវទទួលប្រាក់បៀវត្សរ៍ប្រចាំខែស្របតាមទំហំការងារ និងភារកិច្ចដែលខ្លួនទទួលខុសត្រូវ។ ការកំណត់ចំនួនប្រាក់បៀវត្សរ៍គឺជាសមត្ថកិច្ចរបស់ថ្នាក់ដឹកនាំសមាគម តាមថវិការបស់សមាគម និងស្ថានភាពជាក់ស្តែងរបស់ដៃគូគាំទ្រ (តាមកិច្ចសន្យាការងារ)។

ប្រការ ៧.-

ថ្នាក់ដឹកនាំសមាគមមានសិទ្ធិជ្រើសរើសទីប្រឹក្សា និង/ឬបុគ្គលិកស្ម័គ្រចិត្តដើម្បីជួយការងាររបស់សមាគមតាមការចាំបាច់។

## ២-អំពីប្រាក់ភាគទាន បរិច្ចាគទាន ជំនួយឥតសំណង និងទ្រព្យសម្បត្តិ

ប្រការ ៨.-

សមាជិកទាំងអស់របស់សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត មានកាតព្វកិច្ចបង់ប្រាក់ភាគទានប្រចាំឆ្នាំតាមការកំណត់របស់គណៈកម្មាធិការប្រតិបត្តិជាតិជូនសមាគមរៀងរាល់ដើមត្រីមាសទី២ នៃឆ្នាំនីមួយៗ។

ប្រការ ៩.-

អគ្គលេខាធិការ មានភារកិច្ចទទួលកត់ត្រាឲ្យបានត្រឹមត្រូវនូវចំនួនប្រាក់ និង សម្ភារៈមកពីប្រភពនានារបស់សមាគម ដូចជា ភាគទាន បរិវិសទាន វិភាគទាន មរតក សាសន៍ អតិរេក ឬប្រាក់សន្សំពីកម្មវិធី ចំណូលបានមកពីសកម្មភាពស្របច្បាប់របស់ សមាគម វិភាជន៍ពីរាជរដ្ឋាភិបាល ទីភ្នាក់ងារផ្តល់ជំនួយ ប្រភពស្របច្បាប់ផ្សេងទៀត ដែលមិនធ្វើឱ្យប៉ះពាល់ដល់ឯករាជ្យភាពរបស់សមាគម និងសម្ភារៈ មធ្យោបាយរបស់ រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានផ្តល់ជូនសមាគម។

ប្រការ ១០.-

សមាជិកក្រុមប្រឹក្សាជាតិ សមាជិកគណៈកម្មាធិការប្រតិបត្តិជាតិ បុគ្គលិក និង/ឬ ទីប្រឹក្សាសមាគម ដែលត្រូវបានចាត់ឱ្យទៅបំពេញបេសកកម្ម អាចទទួលបានប្រាក់ បេសកកម្ម។

ប្រធានសមាគម ជាអ្នកសម្រេចផ្តល់ប្រាក់បេសកកម្មតាមគោលនយោបាយគ្រប់គ្រង រដ្ឋបាល និងហិរញ្ញវត្ថុរបស់សមាគម និងតាមគោលការណ៍របស់ដៃគូគាំទ្រ។

## ៣-អំពីការងាររដ្ឋបាល និងហិរញ្ញវត្ថុ

ប្រការ ១១.-

សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវមានគោលនយោបាយគ្រប់គ្រង រដ្ឋបាល និងហិរញ្ញវត្ថុរបស់ខ្លួន ដែលអនុម័តដោយក្រុមប្រឹក្សាជាតិ។

រាល់ការចំណាយថវិការបស់សមាគម ត្រូវគោរពតាមគោលនយោបាយគ្រប់គ្រង រដ្ឋបាល និងហិរញ្ញវត្ថុ។

ប្រការ ១២.-

អគ្គលេខាធិការ ត្រូវទទួលខុសត្រូវលើការងាររដ្ឋបាល និងហិរញ្ញវត្ថុ ស្របតាម គោលនយោបាយគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុរបស់សមាគម។

ប្រការ ១៣.-

អគ្គលេខាធិការ ត្រូវធ្វើរបាយការណ៍សកម្មភាព និងហិរញ្ញវត្ថុ ដាក់ជូនថ្នាក់ដឹកនាំ សមាគម គណៈកម្មាធិការប្រតិបត្តិជាតិ ក្រុមប្រឹក្សាជាតិ មហាសន្និបាត ក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធនានា។

អគ្គលេខាធិការត្រូវចុះបញ្ជីសារពើភ័ណ្ឌ អចលនទ្រព្យ សម្ភារៈ ឲ្យបានទៀងទាត់ជារៀងរាល់ឆមាស និងប្រចាំឆ្នាំ។

## ៤-អំពីគណនីសមាគម

ប្រការ ១៤.-

សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវបើកគណនីនៅធនាគារណាមួយនៅក្នុងប្រទេសកម្ពុជា ដែលមានការទទួលស្គាល់ជាផ្លូវការពីធនាគារជាតិនៃកម្ពុជា និងមានសាខារបស់ខ្លួននៅតាមបណ្តារាជធានី ខេត្ត។

## ៥-អំពីសវនកម្ម

ប្រការ ១៥.-

គណៈកម្មាធិការប្រតិបត្តិជាតិត្រូវជ្រើសរើស និងអនុម័តសវនករផ្ទៃក្នុងរបស់សមាគម។ សវនករផ្ទៃក្នុង ត្រូវធ្វើសវនកម្មលើការគ្រប់គ្រងរដ្ឋបាល និងប្រតិបត្តិការហិរញ្ញវត្ថុរបស់សមាគម។ របាយការណ៍សវនកម្មផ្ទៃក្នុងត្រូវដាក់ជូនថ្នាក់ដឹកនាំសមាគម គណៈកម្មាធិការប្រតិបត្តិជាតិ និងក្រុមប្រឹក្សាជាតិ ដើម្បីពិនិត្យ ពិភាក្សា និងអនុម័តរៀងរាល់ឆ្នាំសារពើពន្ធ។ ច្បាប់ចម្លងរបាយការណ៍សវនកម្មផ្ទៃក្នុង ត្រូវផ្តល់ជូនសមាជិកសមាគម ក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធនានា។

ប្រការ ១៦.-

គណៈកម្មាធិការប្រតិបត្តិជាតិ ត្រូវតែងតាំងសវនករដើម្បីធ្វើសវនកម្មលើកិច្ចការទូទៅរបស់សមាគមតាមការចាំបាច់។

## ៦-អំពីមហាសន្និបាតសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត

ប្រការ ១៧.-

មហាសន្និបាតសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត លើកទី១ មានប្រតិភូចូលរួមមកពីក្រុមប្រឹក្សារាជធានី ខេត្ត។

ចំនួនប្រតិភូចូលរួមមហាសន្និបាតលើកទី១ ត្រូវកំណត់ដោយក្រុមការងារថ្នាក់ជាតិ។

មហាសន្និបាត ប្រព្រឹត្តទៅបានក្រោមការដឹកនាំ និងសម្របសម្រួលរបស់ប្រធាន អនុប្រធានក្រុមការងារថ្នាក់ជាតិ។

បន្ទាប់ពីមហាសន្និបាត បានបង្កើតសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត រួចហើយ មហាសន្និបាតសាមញ្ញ និងវិសាមញ្ញ សមាគមត្រូវអនុវត្តតាមលក្ខន្តិកៈ។

## ៧. អំពីកិច្ចប្រជុំ

*ប្រការ ១៨.-*

កិច្ចប្រជុំរបស់ក្រុមប្រឹក្សាជាតិ អាចប្រព្រឹត្តទៅបានលុះត្រាតែមានសមាជិកចូលរួមប្រជុំលើសពីពាក់កណ្តាលនៃសមាជិកទាំងមូល។

ការសម្រេចក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាជាតិ ដែលយកជាបានការលុះត្រាតែមានការគាំទ្រយ៉ាងតិចហាសិបភាគរយបូកមួយ ក្នុងចំណោមសមាជិកចូលរួមក្នុងកិច្ចប្រជុំ។

*ប្រការ ១៩.-*

កិច្ចប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិជាតិ អាចប្រព្រឹត្តទៅបានលុះត្រាតែមានសមាជិកចូលរួមប្រជុំលើសពីពាក់កណ្តាលនៃសមាជិកទាំងមូល។

ការសម្រេចក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិជាតិដែលយកជាបានការលុះត្រាតែមានការគាំទ្រយ៉ាងតិចហាសិបភាគរយបូកមួយ ក្នុងចំណោមសមាជិកចូលរួមក្នុងកិច្ចប្រជុំ។

## ៨. អំពីការបោះឆ្នោត

*ប្រការ ២០.-*

ការបោះឆ្នោតត្រូវរៀបចំឱ្យមានគណៈកម្មការបោះឆ្នោត។ សមាសភាពគណៈកម្មការបោះឆ្នោត និងនីតិវិធីបោះឆ្នោត ត្រូវសុំការអនុម័តពីមហាសន្និបាតសមាគម។

*ប្រការ ២១.-*

ប្រធានគណៈកម្មការបោះឆ្នោត ត្រូវបែងចែកភារកិច្ចដល់សមាជិកគណៈកម្មការបោះឆ្នោតក្នុងដំណើរការបោះឆ្នោតនីមួយៗ ឱ្យទទួលការងារៈ

- បង្ហាញហិបឆ្នោត
- អានឈ្មោះបេក្ខជនឈរឈ្មោះ
- ចែកសន្លឹកឆ្នោត
- បង្ហាញ និងណែនាំពីលក្ខណៈនៃសន្លឹកឆ្នោត និងរបៀបគូសសន្លឹកឆ្នោតដែលចាត់ទុកជាបានការ និងមិនបានការ

- ពិនិត្យ និងរាប់សន្លឹកឆ្នោតដែលបានបោះគាំទ្រ មិនគាំទ្រ បានការ និង
មិនបានការ
- រៀបចំកំណត់ហេតុស្តីពីលទ្ធផលនៃការបោះឆ្នោត និងអានកំណត់ហេតុ
ជូនអង្គមហាសន្និបាត។

## ៩-អំពីការបាត់បង់សមាជិកភាពប្រធាន ឬអនុប្រធានសមាគម ឬសមាជិកក្រុមប្រឹក្សាជាតិ ឬសមាជិកគណៈកម្មាធិការប្រតិបត្តិជាតិ

ប្រការ ២២.-

ក្នុងករណីបាត់បង់សមាជិកភាពប្រធានសមាគម ថ្នាក់ដឹកនាំសមាគម ត្រូវបើកកិច្ច
ប្រជុំ ដើម្បីពិនិត្យ ពិភាក្សា និងសម្រេចជ្រើសរើសអនុប្រធានណាម្នាក់ឱ្យទទួលជាប្រធាន
ស្តីទី។

គណៈកម្មាធិការប្រតិបត្តិជាតិ ត្រូវបោះឆ្នោតបំពេញបន្ថែមប្រធាន និងអនុប្រធាន
ពេញសិទ្ធិ។

ក្នុងករណីបាត់បង់សមាជិកភាពអនុប្រធានសមាគម គណៈកម្មាធិការប្រតិបត្តិ
ជាតិត្រូវបើកកិច្ចប្រជុំដើម្បីពិនិត្យ ពិភាក្សា និងសម្រេចជ្រើសរើសសមាជិកពីក្នុងគណៈ
កម្មាធិការប្រតិបត្តិជាតិ ឱ្យទទួលជាអនុប្រធានសមាគម។

ប្រការ ២៣.-

សមាជិកក្រុមប្រឹក្សាជាតិ ឬគណៈកម្មាធិការប្រតិបត្តិជាតិ ដែលបាត់បង់
សមាជិកភាពរបស់ខ្លួន ថ្នាក់ដឹកនាំសមាគម ត្រូវប្រជុំពិនិត្យ និងដាក់ជូនអង្គប្រជុំគណៈ
កម្មាធិការប្រតិបត្តិជាតិ ដើម្បីពិនិត្យ ពិភាក្សា និងសម្រេចបំពេញបន្ថែម។

## ១០-អន្តរប្បញ្ញត្តិ

ប្រការ ២៤.-

បន្ទាប់ពីសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវបានបង្កើតឡើងជាផ្លូវការ
ក្រុមការងារថ្នាក់ជាតិបង្កើតសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ នឹងត្រូវបន្តការកិច្ច
ក្នុងការបង្កើតសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ។

ប្រការ ២៥.-

បទបញ្ជាផ្ទៃក្នុងនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មិនា ឆ្នាំ ២០១៣....

ប្រធាន

ឈាំ ទុំ